**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ...៤៩៧៣សហវ.អលក

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ២០១៧

**ជម្រាបជូន**

**ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជា**

**ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា**

**កម្មវត្ថុ៖** ករណីសំណើសុំអនុម័តលទ្ធផលដេញថ្លៃ និងចុះកិច្ចសន្យា ជាមួយក្រុមហ៊ុន HEIG & CCPG ដើម្បីម៉ៅការផ្គត់ផ្គង់សម្ភារ និងសាងសង់អនុស្ថានីយ៍អគ្គិសនីជ្រោយចង្វារ 115/22kV។

**យោង** :
- កំណត់ហេតុបើកឯកសារដេញថ្លៃ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៦ របស់គណៈកម្មាធិការលទ្ធកម្ម អគ្គិសនីកម្ពុជា
- កំណត់ហេតុវាយតម្លៃប្រគល់កិច្ចសន្យា ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៧ របស់គណៈកម្មាធិការលទ្ធកម្ម អគ្គិសនីកម្ពុជា
- លិខិតលេខ៤៤២៣ លស.អក.លក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៧ របស់អគ្គិសនីកម្ពុជា ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តមប្រតិភូមេត្តាជ្រាបថា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុយល់ព្រមតាមសំណើរបស់អគ្គិសនីកម្ពុជា ប្រគល់កិច្ចសន្យាជូនក្រុមហ៊ុន HEIG & CCPG ដើម្បីម៉ៅការផ្គត់ផ្គង់សម្ភារ និងសាងសង់ អនុស្ថានីយ៍អគ្គិសនីជ្រោយចង្វារ 115/22kV ក្នុងតម្លៃសរុបចំនួន ៦ ៤២៨ ៦៨៨.០០ USD (ប្រាំមួយលាន បួនរយម្ភៃប្រាំបីពាន់ ប្រាំមួយរយប៉ែតសិបប្រាំបី ដុល្លារអាមេរិកគត់)ជាតម្លៃកិច្ចសន្យា ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមប្រតិភូមេត្តាជ្រាប និងមានវិធានការអនុវត្តបន្តឱ្យសមស្របតាមនីតិវិធីលទ្ធកម្មសាធារណៈតាមការគួរ ។

សូមឯកឧត្តមប្រតិភូទទួលនូវការរាប់អានពីខ្ញុំ។

**ជ. ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អនុរដ្ឋលេខាធិការ**

**ហ៊ឹម សុវណ្ណ**

**ចម្លងជូន:**
- អគ្គនាយកដ្ឋានពន្ធដារ
- ក្រុមហ៊ុនHEIG & CCPG
- ឯកសារ-កាលប្បវត្តិ